ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៥ សហវ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០០៤

# សេចក្ដីជូនដំណឹង

ដោយអនុលោមតាមសេចក្ដីជូនដំណឹងលេខ ០០១ សហវ.សជណ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ម្ចាស់យានយន្តគ្រប់ប្រភេទមួយចំនួនដែលកន្លងមកខកខានពុំទាន់បានបំពេញកាតព្វកិច្ចពន្ធ និងអាករនាំចូលស្របតាមច្បាប់ជាធរមាននោះ បានចូលខ្លួនជាបន្តបន្ទាប់មកបំពេញបែបបទ និងបង់ពន្ធជូនរដ្ឋរួចហើយ ប្រកបដោយលទ្ធផលគួរឱ្យកត់សំគាល់ ។ ទន្ទឹមនឹងនេះ ក៏នៅមានម្ចាស់យានយន្តមួយចំនួនទៀតមិនទាន់បានចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធតាមការអញ្ជើញនៅឡើយ ។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងដើម្បីសំរួលដល់ឱ្យម្ចាស់យានយន្តដែលខកខានមិនបានអនុវត្តតាមកាលកំណត់នៅឡើយនោះ មានលទ្ធភាពអាចបន្តចូលខ្លួនដោយស្ម័គ្រចិត្តមកបំពេញកាតព្វកិច្ចពន្ធបានផងនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំបន្ថែមដូចតទៅ ៖

១. ម្ចាស់យានយន្តនានាដែលមានបំណងចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធ និងអាករនាំចូលលើយានយន្តរបស់ខ្លួន ត្រូវមកសុំការអនុញ្ញាតបង់ពន្ធរថយន្តរបស់ខ្លួនជាមុននៅតាមការិយាល័យ ឬសាខាគយនិងរដ្ឋាករពាក់ព័ន្ធ ។ ទទួលបានការអនុញ្ញាតពីមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចជាលាយលក្ខណ៍អក្សរលើពាក្យសុំនោះហើយ ទើបប្រើប្រាស់ឯកសារនោះសំរាប់អមភ្ជាប់រថយន្តនាំសំដៅមកកាន់ការិយាល័យ ឬសាខាគយនិងរដ្ឋាករពាក់ព័ន្ធដែលជិតបំផុត ដើម្បីធ្វើការត្រួតពិនិត្យបំពេញបែបបទបង់ពន្ធ និងបិតស្លាកប៉័ត្រជូនភ្លាម ។ ការបញ្ជាក់ពីការអនុញ្ញាតឱ្យចូលខ្លួនមកបង់ពន្ធនោះ ត្រូវមានសុពលភាពយ៉ាងយូរត្រឹម ០៧ ថ្ងៃប៉ុណ្ណោះ គិតពីកាលបរិច្ឆេទនៃការបញ្ជាក់នេះ ។

២. ទីចាត់ការគយនិងរដ្ឋាករ ត្រូវចាត់វិធានការនានាស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមានបន្ថែមទៀត រួមទាំងការអនុវត្តន៍នីតិវិធីតាមផ្លូវតុលាការ ដើម្បីបង្ខំឱ្យម្ចាស់យានយន្តល្មើសទាំងនោះបង់ពន្ធអាករ និងប្រាក់ពិន័យនានាចូលថវិការដ្ឋឱ្យមានប្រសិទ្ធភាពចាប់ពីពេលនេះតទៅ ។ ក្នុងករណីចាំបាច់ កិច្ចការនេះត្រូវធ្វើឡើងដោយមានកិច្ចសហការចូលរួមពីកំលាំងប្រដាប់អាវុធ និងអាជ្ញាធរមានសមត្ថកិច្ចជំនាញ ឬសមត្ថកិច្ចមូលដ្ឋានផងដែរ ស្របតាមខ្លឹមសារលិខិតបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីវិធានការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ។

៣. កំលាំងប្រតិបត្តិការដូចមានចែងក្នុងចំណុច ២ ខាងលើ នឹងត្រូវទទួលបាននូវប្រាក់រង្វាន់លើកទឹកចិត្ត ស្របតាមខ្លឹមសារប្រកាសលេខ ២១១ សហវ.ប្រក.គរ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមថា សេចក្តីណែនាំ និងវិធានការទាំងនេះនឹងទទួលបាននូវការឆ្លើយតបជាវិជ្ជមានពីភាគីពាក់ពន្ធ័ ដោយសូមចាត់ទុកថា ជាការចូលរួមដោយផ្ទាល់ក្នុងការកាត់បន្ថយនឹងឈានទៅលុបបំបាត់អំពើល្មើសច្បាប់ ឬអំពើមិនប្រក្រតីនានាក្នុងសង្គមកម្ពុជា ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជ្រាបជាពត៌មាន )
- ទីចាត់ការគយនិងរដ្ឋាករ ( ដើម្បីចាត់ចែង អនុវត្តតាមមុខការ )
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
  ( ដើម្បីជ្រាបនិងសុំកិច្ចសហការផ្សព្វផ្សាយ )
- ឯកសារ-កាលប្បវត្តិ